ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ បព ៦០/២០២៥ កបទ.សអ

សេចក្ដីប្រកាសព័ត៌មាន

# លទ្ធផលនៃកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីលើកទី២ រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេស និងពាណិជ្ជកម្មហុងគ្រី

រដ្ឋធានីប៊ុយដាប៉ែស ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៥៖ **លោកជំទាវ ជ្រឹង បុទុមរង្សី** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តម ភីធឺ ស្តារ៉េ** (Péter Sztáray) រដ្ឋលេខាធិការទទួលបន្ទុកគោលនយោបាយសន្តិសុខ និងសន្តិសុខថាមពល នៃក្រសួងការបរទេស និងពាណិជ្ជកម្មហុងគ្រី បានធ្វើជាសហប្រធាននៃកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីលើកទី២ រវាងក្រសួងការបរទេសនៃប្រទេសទាំងពីរ។

ភាគីទាំងពីរបានសម្តែងនូវសេចក្តីពេញចិត្តចំពោះមិត្តភាពដ៏យូរអង្វែង និងកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើររវាងប្រទេសទាំងពីរ ខណៈដែលកម្ពុជា និងហុងគ្រីនឹងប្រារព្ធខួបលើកទី៧០ នៃទំនាក់ទំនងការទូតនៅឆ្នាំ២០២៦។ លោកជំទាវ ជ្រឹង បុទុមរង្សី បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមចំណែកដ៏មានតម្លៃរបស់ហុងគ្រី ក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា។

ភាគីទាំងពីរបានផ្លាស់ប្តូរទស្សនៈលើវិសាលភាពទូលំទូលាយនៃវិស័យនយោបាយ សេដ្ឋកិច្ច និងការអភិវឌ្ឍ និងវិស័យសក្តានុពលជាច្រើនទៀត ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ រួមមានពាណិជ្ជកម្ម និងការវិនិយោគ ការគ្រប់គ្រងធនធានទឹក កសិកម្ម និងកសិឧស្សាហកម្ម ថាមពល អប់រំ សុខាភិបាល ទេសចរណ៍។ ថ្នាក់ដឹកនាំទាំងពីរក៏បានឯកភាពពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិផងដែរ។

ភាគីទាំងពីរក៏បានគូសបញ្ជាក់ពីសារៈសំខាន់នៃយន្តការដែលមានស្រាប់ដូចជា គណៈកម្មាធិការចម្រុះស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងវេទិកាធុរកិច្ច ក្នុងការស្វែងរកមធ្យោបាយថ្មីៗនៃកិច្ចសហប្រតិបត្តិការ។

សហប្រធានទាំងពីរបានពិភាក្សាអំពីបញ្ហាតំបន់ និងអន្តរជាតិសំខាន់ៗ ដែលជាក្តីកង្វល់រួម ដោយបានបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរួមគ្នា ក្នុងការលើកកម្ពស់សន្តិភាព និងស្ថិរភាព នៅក្នុងតំបន់ និងអន្តរជាតិ តាមរយៈកិច្ចសន្ទនាបែបស្ថាបនា និងកិច្ចសហប្រតិបត្តិការជិតស្និទ្ធ។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

អំពីស្ថានភាពព្រំដែនកម្ពុជា-ថៃ ឯក**ឧត្តម ភីធី ស្តារ៉េ** បានគូសបញ្ជាក់អំពីសារៈសំខាន់នៃកិច្ចសន្ទនាដោយសន្តិវិធី និងបានលើកទឹកចិត្តឱ្យភាគីទាំងពីររក្សាការប្តេជ្ញាចិត្តចំពោះការដោះស្រាយជម្លោះដោយសន្តិវិធី។

ភាគីទាំងពីរទទួលនឹងរៀបចំកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីជុំបន្ទាប់ ដែលនឹងប្រព្រឹត្តទៅនៅកម្ពុជា នៅពេលវេលាសមស្រប។

ថ្ងៃអង្គារ ៥ កើត ខែ មិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥